# សេចក្តីថ្លែងការណ៍របស់ស្ថានទូតអាមេរិក នៅភ្នំពេញ
## ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០២៣

★ ★ ★ ★

យើងមានការរំខានចិត្តជាខ្លាំង ដោយការសម្រេចចិត្តភ្លាមៗ ក្នុងការដកអាជ្ញាប័ណ្ណពីសារព័ត៌មានសម្លេងប្រជាធិបតេយ្យ VOD ។

សារព័ត៌មានដែលមានភាពសេរី និងឯករាជ្យ ដើរតួនាទីសំខាន់ចាំបាច់ នៅក្នុងលទ្ធិប្រជាធិបតេយ្យត្រឹមត្រូវមួយ ដោយផ្តល់ឲ្យសាធារណជន និងអ្នកសម្រេចចិត្ត ឲ្យដឹងការពិត ហើយធ្វើឲ្យរដ្ឋាភិបាលមានការទទួលខុសត្រូវ។

អស់រយៈពេលជាង ២០ ឆ្នាំមកហើយ ដែលសារព័ត៌មាន VOD បានធ្វើសេចក្តីរាយការណ៍ដោយមិនលម្អៀង ហើយឈរលើការពិត លើបញ្ហាដែលបម្រើប្រយោជន៍ប្រជាជនកម្ពុជា។

យើងសូមអំពាវនាវឲ្យអាជ្ញាធរកម្ពុជាពិនិត្យមើលឡើងវិញ នូវការសម្រេចចិត្តនេះ។